ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# មាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ៥នាក់ ពីប្រទេសម៉ាឡេស៊ី

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៥នាក់** ដូចខាងក្រោម៖

**(១)** ពលការិនី **ហ.ម** អាយុ៣០ឆ្នាំ មកពីស្រុកកោះសូទិន ខេត្តកំពង់ចាម បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក នាងបានទៅស្ថានទូត នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ សុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ និយោជករបស់ពលការិនីបានយល់ព្រមប្រគល់លិខិតឆ្លងដែន និងប្រាក់ខែដែលនៅសល់ ជូននាង។

**(២)** ពលការិនិ **ស.ស** អាយុ៣៧ឆ្នាំ មកពីស្រុកបរសែត ខេត្តកំពង់ធំ បានទៅម៉ាឡស៊ី ធ្វើការជាអ្នកបោសសំអាត ពីឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយពុំមានអ្នកថែរក្សាកូនស្រីរបស់ខ្លួននៅកម្ពុជា ពលការិនីបានស្នើស្ថានទូត នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ សុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

**(៣)** ពលការិនី **វ.វ.ក** អាយុ២២ឆ្នាំ មកពីខេត្តកំពង់ធំ បានទៅម៉ាឡេស៊ី ធ្វើការតាមផ្ទះ ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៥ តាមរយៈមេខ្យល់ម្នាក់។ ដោយនិយោជករបស់ពលការិនី ធ្វើទិដ្ឋាការការងារក្លែងក្លាយជូននាង ហេតុនេះនាងសម្រេចឈប់ធ្វើការ និងបានទៅស្ថានទូតនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ សុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

**(៤)** ពលការិនី **គ.ស** អាយុ៣៣ឆ្នាំ មកពីស្រុកចន្ទ្រា ខេត្តស្វាយរៀង បានទៅម៉ាឡេស៊ីដោយខ្លួនឯង ធ្វើការនៅក្នុងភោជនីយដ្ឋាន ពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៦។ ដោយសារពលការិនីនឹកផ្ទះនិងក្រុមគ្រួសារ នាងបានស្នើស្ថានទូត នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ សុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ ។

ពលការិនី**៤នាក់**ខាងលើ បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** ថ្ងៃទី **១៥** ខែ **មករា** ឆ្នាំ **២០១៧** វេលាម៉ោង**០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

**(៥)** ពលការិនី **ហ.ភ.រ** អាយុ៣៧ឆ្នាំ មកពីស្រុករមាសហែក ខេត្តស្វាយរៀង បានទៅម៉ាឡេស៊ី និងធ្វើការងារតាមផ្ទះតាំងពីឆ្នាំ២០១៤ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយនិយោជករបស់ខ្លួន បានប្រើអំពើហឹង្សា ពលការិនីបានលួចរត់ចេញពីផ្ទះ និងដើរតាមផ្លូវ ហើយត្រូវបាននគរបាលរដ្ឋ Selangor ជូនទៅស្ថានទូតនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦។ ស្ថានទូតពិបាកក្នុងការទាមទារសំណង ឬប្រាក់ខែដែលនៅសល់ពីនិយោជកសម្រាប់ពលការិនី ដោយសារនាងពុំចងចាំឈ្មោះនិងអាស័យដ្ឋានទាក់ទងរបស់និយោជកខ្លួនឡើយ ។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ព្រមទាំងបានឧបត្ថម្ភសំបុត្រយន្តហោះ កន្លែងស្នាក់នៅ អាហារបរិភោគ និងថវិកាមួយចំនួន ដល់ពលការិនី អំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ។

ពលការិនី **ហ.ភ.រ** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៤** ខែ**មករា** ឆ្នាំ**២០១៧** វេលាម៉ោង**០៧:៥០** នាទីព្រឹក តាមជើងយន្តហោះ AK536 ៕

ភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ